# ធម្មទេសនារបស់លោកអធិបាល អូលីវីយេ
# អធិបូជាចិនសិក្ខាសាលាព្រះគម្ពីរ
# ភ្នំពេញថ្មី ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩
# តើព្រះបន្ទូលថ្ងៃនេះប៉ះពាល់ដល់ជីវិតរបស់ខ្ញុំដូចម្ដេច?

**អត្ថបទទី១៖ ធីម៉ូថេទី២ ៤,១០-១៧ខ**

មានតែព្រះអម្ចាស់ប៉ុណ្ណោះដែលបានគាំទ្រ និងប្រទានឲ្យខ្ញុំមានកម្លាំង ដើម្បីឲ្យខ្ញុំអាចប្រកាសព្រះបន្ទូលយ៉ាងក្បោះក្បាយឲ្យសាសន៍ដទៃទាំងអស់គ្នាស្ដាប់។ ២ធម ៤,១៧ខ

**ដំណឹងល្អ៖ លូកា ១០,១-៩**

ពេលអ្នករាល់គ្នាចូលទៅក្នុងផ្ទះណាមួយ មុនដំបូងត្រូវពោលថា "សូមព្រះជាម្ចាស់ប្រទានសេចក្ដីសុខសាន្ដ ដល់មនុស្សក្នុងផ្ទះនេះ" ។ លក ១០,៥

បងប្អូនជាទីស្រឡាញ់!

នៅពេលយើងអានគម្ពីរដំណឹងល្អរបស់សន្ដទាំងបួនរួចហើយ យើងថានេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ដជាអម្ចាស់ ក្រោយមកលោកបូជាចារ្យថើប។ មានន័យថា នេះជាព្រះបន្ទូលយើងត្រូវការគោរព ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយើងបានស្ដាប់យ៉ាងស្ងៀមស្ងាត់ ដោយទូលអង្វរព្រះអង្គឲ្យព្រះបន្ទូលនេះបំភ្លឺយើង។ អ្វីដែលសំខាន់បំផុត គឺឲ្យយើងយល់ថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាព្រះបន្ទូលដ៏មានជីវិតនៅក្នុងជីវិតរបស់យើងសព្វថ្ងៃ។ ព្រះបន្ទូលខ្លះដែលយើងបានស្ដាប់នៅក្នុងសម្ពន្ធមេត្រីចាស់ យើងត្រូវការគិតថាព្រះបន្ទូលដែលមានអាយុ៣០០០ឆ្នាំ មានអត្ថន័យដូចម្ដេចសម្រាប់យើងថ្ងៃនេះ។ សម្រាប់យើងដែលជាគ្រីស្ដបរិស័ទ យើងមិនគោរពគម្ពីរដំណឹងល្អដែលជាសៀវភៅមួយ យើងត្រូវការទុកនៅកន្លែងសក្ការៈ តែជាសៀវភៅមួយដែលយើងត្រូវការស្ដាប់ ទទួលនៅក្នុងដួងចិត្តរបស់យើង និងពិចារណា **តើព្រះបន្ទូលនេះមានអត្ថន័យដូចម្ដេចសម្រាប់ជីវិតខ្ញុំ?**

អត្ថបទទីមួយថ្ងៃនេះ "**មានតែព្រះអម្ចាស់ប៉ុណ្ណោះដែលបានគាំទ្រ និងប្រទានឲ្យខ្ញុំមានកម្លាំងដើម្បីឲ្យខ្ញុំអាចប្រកាសព្រះបន្ទូលយ៉ាងក្បោះក្បាយ ឲ្យសាសន៍ដទៃទាំងអស់គ្នាស្ដាប់**"។ នៅពេលខ្ញុំស្ដាប់អត្ថបទទីមួយនេះ មានអត្ថន័យសម្រាប់ជីវិតរបស់ខ្ញុំ ពេលខ្លះយើងមានអារម្មណ៍ថាយើងឯកោ តែយើងដឹងថាយើងមានព្រះជាម្ចាស់ដែលគង់នៅជាមួយយើង ចាំជួយគាំទ្រយើង។ នេះជាបេសកកម្មរបស់ខ្ញុំដែល ដើម្បីប្រកាសព្រះបន្ទូលយ៉ាងក្បោះក្បាយដល់សាសន៍ដទៃ ខ្ញុំត្រូវការធ្វើដូចម្ដេច ដើម្បីឲ្យបងប្អូនដែលមិនមែនជាគ្រីស្ដបរិស័ទបានស្ដាប់ព្រះបន្ទូលដំណឹងល្អនេះ។ យើងត្រូវការគិតផ្ទាល់ខ្លួន **តើខ្ញុំជាគ្រីស្ដបរិស័ទខ្ញុំធ្វើដូចម្ដេចដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់**

**ទៅដល់បងប្អូនឯទៀតៗ?** ថ្ងៃនេះ យើងមើលរបៀបដែលព្រះយេស៊ូឲ្យសាវ័កពីដើមទៅប្រកាសដំណឹងល្អ "**សូមទៅតាមភូមិ ទៅតាមផ្ទះ ពេលទៅដល់ផ្ទះរបស់គេសូមប្រកាសអំពីសេចក្តីសុខសាន្ត**" សូមជូនពរឲ្យបងប្អូនពោរពេញដោយសេចក្តីសុខសាន្ត ឲ្យគេដឹងថាព្រះរាជ្យរបស់ព្រះជាម្ចាស់ជិតមកដល់ហើយ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺសេចក្តីសុខសាន្តដែលយើងមាននៅក្នុងដួងចិត្ត ប្រសិនបើគេទទួលខ្ញុំខ្ញុំនៅបន្ត ប្រសិនបើគេបណ្តេញខ្ញុំខ្ញុំទៅកន្លែងផ្សេង។ នៅពេលគេស្វាគមន៍ខ្ញុំ ឲ្យខ្ញុំញ៉ាំបាយជាមួយគេ ឲ្យខ្ញុំណែនាំឲ្យអ្នកជំងឺបានជាសះស្បើយ ឲ្យយើងមានសញ្ញាយ៉ាងជាក់ស្តែង។ យើងត្រូវការគិត អ្នកជំងឺដែលយើងបានជួបថ្ងៃនេះយើងជាគ្រីស្តបរិស័ទ យើងធ្វើដូចម្តេចដើម្បីឲ្យគេមានឱកាសទៅដល់មណ្ឌលសុខភាព ទៅដល់មន្ទីរពេទ្យដើម្បីបានទទួលការព្យាបាល។ យើងអាចមើលថាគេមានសេចក្តីត្រូវការអ្វីខ្លះ យើងធ្វើដូចម្តេចដើម្បីផ្តល់សេចក្តីសង្ឃឹមឲ្យគេ នេះជាអ្វីដែលព្រះយេស៊ូសុំពីយើង ឆ្លើយតបសេចក្តីត្រូវការរបស់បងប្អូនឯទៀតៗឲ្យគេពោរពេញដោយសេចក្តីសង្ឃឹមសាជាថ្មី។

មហាជនសប្បាយចិត្តមកស្តាប់ព្រះយេស៊ូ ដោយសារព្រះយេស៊ូបានឆ្លើយតបសេចក្តីត្រូវការរបស់គេ រហូតដល់គេរកឃើញព្រះអម្ចាស់ដែលជាម្ចាស់នៃជីវិតរបស់គេ។ អំពីលោកសាខេព្រះយេស៊ូបានឆ្លើយតបសេចក្តីត្រូវការរបស់គាត់ដើម្បីឲ្យគាត់មានជីវិតថ្មី នៅពេលគាត់បានចែករំលែកទ្រព្យសម្បត្តិដល់បងប្អូនឯទៀតៗគាត់ពោរពេញដោយសេចក្តីសុខ។ លោកបាទីមេ ក៏ដូចគ្នាដែរនៅពេលគាត់បានសូមទូលអង្វរឲ្យគាត់មើលឃើញសាជាថ្មី គាត់បានដូចបំណងរបស់គាត់ណែនាំឲ្យគាត់ពោរពេញដោយសេចក្តីសុខនៅក្នុងជីវិតថ្មី។ នៅពេលព្រះយេស៊ូដើរតាមមាត់បឹងកាលីឡេ ដើម្បីត្រាស់ហៅក្រុមសាវ័ក ឲ្យគេទៅនេសាទមនុស្សដោយធ្វើការជាមួយព្រះអង្គណែនាំឲ្យគេទៅជាមនុស្សថ្មីដែលពោរពេញដោយសេចក្តីសុខសាន្ត។ មហាជន បានមកស្តាប់ព្រះបន្ទូលដ៏មានជីវិតដោយសារគេដឹងថា ព្រះយេស៊ូបានឆ្លើយតបនឹងសេចក្តីត្រូវការរបស់គេនិងព្រះអង្គណែនាំឲ្យគេទៅជាមនុស្សថ្មី។ កូនពៅវង្វេង នៅពេលគាត់បានមកជួបឪពុកណែនាំឲ្យគាត់យល់អំពីតម្លៃនៃជីវិតរបស់គាត់ដែលជាកូនរបស់ឪពុក ណែនាំឲ្យយើងយល់អំពីតម្លៃនៃជីវិតរបស់យើងដែលជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់។

បងប្អូនជាទីស្រឡាញ់!

នៅពេលយើងចូលអភិបូជាម្តងៗ ឲ្យយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយគិត **តើព្រះបន្ទូលនេះជម្រុញខ្ញុំឲ្យខ្ញុំធ្វើអ្វីខ្លះ រស់នៅដូចម្តេចនៅក្នុងជីវិតប្រចាំថ្ងៃជាគ្រីស្តបរិស័ទរបស់ខ្ញុំ?** បើយើងមិនចេះអាន ឲ្យយើងមានឧបករណ៍ណាមួយដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីឲ្យព្រះបន្ទូលទៅជាតែមួយជាមួយយើង។ ច្រើនដង ពេលខ្ញុំសួរគេថា **តើមានព្រះបន្ទូលណា**

**មួយដែលណែនាំឲ្យប៉ះពាល់ដល់ជីវិតរបស់គេ?** គេមិនដឹងថាមានព្រះបន្ទូលណាមួយដែលណែនាំឲ្យគេទៅជាមនុស្សថ្មី ដែលណែនាំឲ្យគេស្រឡាញ់ព្រះយេស៊ូ ដែលណែនាំឲ្យគេមានសេចក្ដីសុខឡើយ។ ព្រះបន្ទូលរបស់ព្រះយេស៊ូស្រួលយល់ណាស់ ដោយសារព្រះយេស៊ូមានព្រះបន្ទូលដល់យើងទាំងអស់ដែលជាមនុស្សលោក ដល់អ្នកតូចតាច ដល់អ្នកដែលគ្មានចំណេះដឹង...។ កុំឲ្យយើងគិតថាព្រះបន្ទូលសម្រាប់តែអ្នកដែលមានចំណេះដឹងខ្ពស់ ព្រះយេស៊ូមានព្រះបន្ទូលសម្រាប់មនុស្សទាំងអស់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដឹកនាំជីវិតរបស់យើងប្រចាំថ្ងៃ។ ព្រះជាម្ចាស់គាំទ្រខ្ញុំ ដើម្បីឲ្យខ្ញុំប្រកាសព្រះបន្ទូលដល់មនុស្សដែលមិនបានស្ដាប់ព្រះបន្ទូលហ្នឹង នៅពេលខ្ញុំប្រកាសព្រះបន្ទូលខ្ញុំត្រូវការជូនសេចក្ដីសុខសាន្ត ខ្ញុំត្រូវការអង្គុយយកពេលវេលានៅជាមួយគេ ស្ដាប់សេចក្ដីត្រូវការរបស់គេ ដើម្បីប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ទៅជាជីវិតប្រចាំថ្ងៃរបស់គេ។ អាម៉ែន៕